# សេចក្តីសង្ខេប

Draft

# សេចក្តីសង្ខេប

## ១. សេចក្តីផ្តើម

ស្របពេលជាមួយគ្នានេះដែរ ផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលបានជំរុញ និងលើកទឹកចិត្តអ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុក ជាពិសេសវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកជួយស្តារ កសាង និងអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យរីកចម្រើន និងបូករួមទាំងការចូលវិនិយោគលើគ្រប់ផ្នែកទាំងអស់ គឺទាំងការវិនិយោគ ផលិតទំនិញនាំចេញ ការផលិតថាមពល ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគផ្នែកទេសចរណ៍ក៏ដូចជាវិស័យសំខាន់ៗដ៏ទៃទៀតដែលជួយជំរុញការអភិវឌ្ឍន៍ និងជំរុញកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាឲ្យមានសន្ទុះលឿនថែមមួយកម្រិតទៀត។

តាមរយៈការជំរុញលើកទឹកចិត្តខ្ពស់បែបនេះ និងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យកសិកម្ម ខេត្តព្រះវិហារក៏មានផែនការ និងគោលដៅដើម្បីអភិវឌ្ឍសេដ្ឋកិច្ចខេត្តសំដៅធ្វើឲ្យមានកំណើនប្រាក់ចំណូលដល់ប្រជាកសិករ ក៏ដូចជាបងប្អូនជនជាតិភាគតិចតាមរយៈការបង្កើនកាលានុវត្តភាពការងារ ការវិនិយោគឯកជន សាធារណៈ និងការពង្រឹងផលិតកម្ម សេវាកម្ម ប្រកបដោយចីរភាព។ ដោយផ្អែកលើលក្ខណៈអំណោយផលនានា ឱកាស និងឆ្លើយតបចំពោះតម្រូវការក្នុងការអភិវឌ្ឍន៍ប្រទេសជាតិក៏ដូចជាការអភិវឌ្ឍន៍ក្នុងតំបន់ ជាពិសេសដើម្បីចូលរួមចំណែកជួយរាជរដ្ឋាភិបាលឲ្យសម្រេចបាននូវទិសដៅ ដែលបានដាក់ចេញ ក្រុមហ៊ុន **ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត** បានពិនិត្យឃើញថាការវិនិយោគគម្រោងដាំដំណាំកសិ-ឧស្សាហកម្ម ដាំដំណាំអំពៅ និងអាកាស្យា ដែលជាការវិនិយោគមួយសមស្របបំផុតនៅភូមិសាស្ត្រ ឃុំតស៊ូ ឃុំស្អាង និងឃុំពុទ្រា ស្រុកជ័យសែន ខេត្តព្រះវិហារ ព្រោះការវិនិយោគនេះស្របជាមួយនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក៏ដូចជាផែនការ និងគោលដៅដើម្បីអភិវឌ្ឍសេដ្ឋកិច្ចខេត្តផងដែរ។

ម្យ៉ាងទៀត ទីតាំងភូមិសាស្ត្រ ស្ថានភាពដីនៅទីនោះអំណោយផល និងអនុគ្រោះច្រើនដល់ការដាំដំណាំកសិ-ឧស្សាហកម្ម និងតម្រូវការនៃដំណាំនេះបច្ចុប្បន្ន កំពុងមានការកើនឡើងជាលំដាប់។

ហេតុនេះ ក្រោយពីបានសិក្សាយ៉ាងល្អិតល្អន់ព្រមទាំងការផ្តល់យោបល់ដោយអ្នកជំនាញបច្ចេកទេសជាច្រើនរូបមកក្រុមហ៊ុនបានសម្រេចវិនិយោគលើការដាំអំពៅ និងអាកាស្យា សម្រាប់សេចក្តីត្រូវការក្នុងប្រទេសក៏ដូចជាការនាំចេញ។

## ២. វិធីសាស្ត្រ និងទំហំនៃការសិក្សាស្រាវជ្រាវ

វិធីសាស្ត្រនៃការសិក្សានេះរួមមាន៖ (១) ការប្រមូលទិន្នន័យមានស្រាប់ពីក្រសួង-ស្ថាប័ន វិទ្យាស្ថានស្រាវជ្រាវ អាជ្ញាធរដែនដីដែលពាក់ព័ន្ធ (២) ការប្រមូលទិន្នន័យគោលតាមរយៈការចុះអង្កេតផ្ទាល់ ការពិគ្រោះយោបល់ ការសម្ភាសន៍ផ្ទាល់ជាមួយក្រុមគោលដៅ ការធ្វើសារពើភណ្ឌព្រៃឈើ ការសិក្សាធនធានសត្វព្រៃ ធនធានជលផល យកសំណាកដី និងយកសំណាកទឹកមកពិនិត្យនៅក្រសួងបរិស្ថាន។ ទិន្នន័យដែលពាក់ព័ន្ធនឹងផែនទីត្រូវបានយកមកវិភាគតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ Geographic Information System(GIS) ។ ទិន្នន័យសង្គមសេដ្ឋកិច្ចត្រូវបានវិភាគវាយតម្លៃតាមបែបរហ័ស (RRA និងPRA) និងវិភាគតាមប្រព័ន្ធកុំព្យូទ័រ Microsoft Excel។

Draft

## ៣. ក្របខណ្ឌច្បាប់

នៅក្នុងបរិបទថ្មីដែលប្រទេសជាតិមានសង្គ្រាមផង សន្តិភាពផង កម្ពុជាបានខិតខំចងក្រងនូវលិខិតបទដ្ឋាននានាបានយ៉ាងច្រើន សម្រាប់យកមកអភិវឌ្ឍប្រទេសឲ្យក្លាយទៅជាប្រទេសនីតិរដ្ឋ។ លិខិតបទដ្ឋានច្បាប់ដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួមមាន ៖ ១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣) ២. ច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៤) ៣. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) ៤. ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ (១៩៩៦) ៥. ច្បាប់ការងារ (១៩៩៧) ៦. ច្បាប់ភូមិបាល (២០០១) ៧. ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ (២០០១) ៨. ច្បាប់ស្តីពីព្រៃឈើ (២០០២) ៩. ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (២០០៣) ១០. ច្បាប់ជលផល (២០០៦) ១១. ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា (២០០៧) ១២. ច្បាប់ស្តីពីជីវសុវត្ថិភាព (២០០៨) ១៣. ច្បាប់ស្តីពីការគ្រប់គ្រង ពូជដំណាំ និងសិទ្ធអ្នកបង្កាត់ពូជដំណាំ (២០០៨) ១៤. ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (២០១២) ១៥. អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (១៩៩៩) ១៦. អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (១៩៩៩) ១៧. អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩) ១៨. អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង (២០០០) ១៩. អនុក្រឹត្យស្តីពីការ គ្រប់គ្រងជីរដ្ឋ (២០០៥) ២០. អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ២១. ប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា (២០០៣) ២២. ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅ ក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង ពេញលេញ ២៣. សេចក្តីសម្រេច ស្តីពីការកំណត់តំបន់ទាំងបី ដើម្បីការពារបេតិកភណ្ឌប្រសាទនៅតាមបណ្តាខេត្ត-ក្រុង ក្រៅពីតំបន់អង្គរសៀមរាប ២៤. គោលនយោបាយចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ២៥. គោលនយោបាយជនជាតិដើមភាគតិច។

## ៤. ការពិពណ៌នាអំពីគម្រោង

ក្រុមហ៊ុនមានឈ្មោះថា ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **HENG NON (CAMBODIA) INTERNATIONAL COMPANY LIMITED** មានទីស្នាក់ការស្ថិតនៅផ្ទះលេខ ៣៥A ផ្លូវលេខ ៣២៨ សង្កាត់ ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមានទូរសព្ទ័ទំនាក់ទំនងលេខ : (៨៥៥-២៣) ៩៨៦ ២៣៦។

ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **HENG NONG (CAMBODIA) INTERNATIONAL COMPANY LIMITED** បានស្នើសុំដីសម្បទានសេដ្ឋកិច្ចពីរដ្ឋាភិបាលកម្ពុជាតាមរយៈឯកឧត្តមអភិបាលខេត្ត និងឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើទំហំផ្ទៃដីចំនួន ៦.៤៨៨ ហិកតា សម្រាប់ដំណើរការវិនិយោគដំណាំកសិ-ឧស្សាហកម្ម (ដាំដំណាំអំពៅ និងអាកាស្យា) ដែលសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនបានស្នើសុំនេះ មានទីតាំងស្ថិតក្នុងស្រុកជ័យសែន ខេត្តព្រះវិហារ។ ទីតាំងខាងលើមានចម្ងាយ ប្រហែល ៤២ គីឡូម៉ែត្រពីទីរួមខេត្តព្រះវិហារ។

Draft

ក្រុមហ៊ុនរៀបចំលើផ្ទៃដីសម្រាប់អាជីវកម្ម-ផលិតកម្មចំនួន ៦.៤៨៨ ហិកតា។ លើផ្ទៃដីនេះក្រុមហ៊ុនធ្វើការបែងចែកជា ០៥ អនុតំបន់ សម្រាប់ធ្វើការដាំដុះតាមឆ្នាំនីមួយៗ និងការបែងចែកទំហំផ្ទៃដីសម្រាប់ដាំដុះតាមអនុតំបន់នីមួយៗមានដូចខាងក្រោម ៖ អនុតំបន់ទី I មានផ្ទៃដីសរុបចំនួន ៧៦១ ហិកតា, អនុតំបន់ទី II មានផ្ទៃដីសរុបចំនួន ៥៦៩ ហិកតា, អនុតំបន់ទី III មានផ្ទៃដីសរុបចំនួន ១.៣៥៦ ហិកតា, អនុតំបន់ទី IV មានផ្ទៃដីសរុបចំនួន ២.២៩៤ ហិកតា, អនុតំបន់ទី V មានផ្ទៃដីសរុបចំនួន ៧.៣៤០ ហិកតា។

- ដំណាំអំពៅ

បច្ចុប្បន្នក្រុមហ៊ុនប្រើប្រាស់ពូជអំពៅចំនួន ០៤ ពូជគឺ ៖ ពូជ KK3, K9211, K9272, និង K9584 ដែលបាននាំចូលពីរោងចក្រស្ករសក្នុំពេញ និងរោងចក្រស្ករស ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺក្នុងឆ្នាំ២០១២។

ក្រុមហ៊ុនមានគោលការណ៍ប្រើប្រាស់ជីគ្រាប់នៅក្នុងអំឡុងពេលដាំដុះ គឺប្រើប្រាស់ប្រភេទជី NPK ១៦-១៦-៨ ទម្ងន់ ៤៥០ Kg ប្រើប្រាស់ជីប្រភេទ NPK ១៥-១៥-២០ ទម្ងន់ ៣០០ Kg នៅពេលផ្សាំដីទំហំតូច និងប្រើប្រាស់ជី NPK ៤០-០-០ ទម្ងន់ ៣០០ Kg នៅពេលផ្សាំដីទំហំធំ។

ក្រុមហ៊ុនកំពុងប្រើប្រាស់ថ្នាំកម្ចាត់ស្មៅប្រភេទ Atrazin,2,4-D Butyl ester, acetocholor, paraquat និងថ្នាំសម្លាប់សត្វល្អិតប្រភេទ Bisultap ។ ដែលថ្លៃចំណាយលើថ្នាំកម្ចាត់ស្មៅ និងថ្នាំសម្លាប់សត្វល្អិតក្នុងការដាំដុះដំណាំអំពៅចំនួន ៧៥ ដុល្លារអាមេរិក/១ហិកតា និងថ្លៃដើមសម្រាប់ដាំដុះក្នុង ១ ហិកតា ជាមធ្យមប្រមាណ ១១០០ ដុល្លារអាមេរិក។ ហើយចំពោះការប្រមូលផល ដំណាំអំពៅត្រូវបានធ្វើឡើងនៅអាយុប្រមាណជា ១០ ទៅ ១៣ ខែ បន្ទាប់ពីការដាំ។

- ដំណាំអាកាស្យា

បច្ចុប្បន្នក្រុមហ៊ុនប្រើប្រាស់អាកាស្យាចំនួន ០២ ពូជគឺ៖ ពូជ U5 និង U6 ដើមទុនក្នុងមួយហិកតាតម្លៃ ៩៦៥ USD/ha និងចំណូល ១,០០០ USD/ha។ ក្រុមហ៊ុនមានគោលការណ៍ប្រើប្រាស់ជីគ្រាប់នៅក្នុងកំឡុងពេលដាំដុះ គឺកូនអាកាស្យានីមួយៗនឹងទទួលបានជី អ៊ិន - បេ - កា (NPK 15.15.15) ១០០ ក្រាម។ ជីត្រូវបានដាក់កម្រាស់ពី ១៥-២០ ស.ម ពីដើមដែលមានបរិមាណ ៥០ ក្រាមខាងឆ្វេង និង៥០ ក្រាមទៀតដាក់ខាងស្តាំ។ ចំពោះកូនអាកាស្យា ដែលបានដាំនៅលើទីចំណោត/ប្រាំង ការដាក់ជីត្រូវដាក់ពីលើទួល។

ក្រោយការដាំរយៈពេលពី ៣-៦ ខែ ស្មៅ រុក្ខជាតិដែលដុះប្រជែងនឹងកូនអាកាស្យាមានកម្ពស់ ០.៥ ម៉ែត្រ ត្រូវធ្វើការកាប់ចោល។ ការធ្វើបែបនេះដើម្បីឲ្យកូនឈើទទួលបាននូវអាហារូបបត្ថម្ភ ដែលមានក្នុងដីនូវកម្រិតអតិបរមាគួបផ្សំជាមួយនឹងការទទួលបានពីពន្លឺថ្ងៃ។ ចម្ការអាកាស្យានឹងបន្តការថែទាំ តាមរយៈការសម្អាតស្មៅ ការដាក់ជីនៅពេលចាំបាច់។ ចំពោះការប្រមូលផលឈើអាកាស្យា បានពន្លឿនការលូតលាស់របស់ខ្លួនរយៈពេល ៥-៦ ឆ្នាំ ដំបូងដែលជាពេលវេលាត្រូវពិចារណាសម្រាប់ធ្វើការប្រមូលផល (កម្ពស់ឈើ ១៨-១៦ ម៉ែត្រ ផល ៩០-១២០ ម$^{៣}$/ហិកតា) ។

## ៥. ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺចាំបាច់ត្រូវយល់ដឹងអំពីស្ថានភាពបរិស្ថានដែលមានស្រាប់នៅក្នុង និងក្បែរតំបន់គម្រោងពោលគឺអាចនឹងយល់ដឹងថា តើការផ្តល់ដីសម្បទាននេះ នឹងអាចបង្កនូវហេតុប៉ះពាល់ជា

Draft

វិជ្ជមាន និងអវិជ្ជមានអ្វីខ្លះ? ហើយអាចឈានដល់ការប្រៀបធៀបអំពីផលប៉ះពាល់ទាំងពីរនេះ រួចនឹងទទួលបាននូវការសម្រេចចិត្តប្រកបដោយប្រសិទ្ធិភាព។ ការសិក្សាលើស្ថានភាពបរិស្ថានសំខាន់ៗមានចំនួន ០៣ គឺ ៖ ធនធានរូបសាស្ត្រ (អាកាសធាតុ ឋានលេខា កូគព្ភសាស្ត្រ និងជលសាស្ត្រ) ធនធានជីវសាស្ត្រ (ធនធានព្រៃឈើ និងធនធានសត្វ) និងធនធានសេដ្ឋកិច្ច-សង្គម ។

<u>ធនធានរូបសាស្ត្រ</u>

អាកាសធាតុ ៖ តាមការសិក្សាជាទិន្នន័យ គោលអាកាសធាតុរបស់មន្ទីធនធានទឹក និងឧតុនិយម ឆ្នាំ២០១០ ដល់ ២០១៥ បានបង្ហាញថា នៅតំបន់គម្រោងមានសីតុណ្ហភាពពីចន្លោះ ៣៥,៨ °C ទៅ ២២,៦៤ °C។ របបទឹកភ្លៀងធ្លាក់ពីចន្លោះ ១.៦៧៨,៨ មម ទៅ ១.២៧៤,៥ មម។ សំណើមបរិយាកាសមធ្យមប្រចាំឆ្នាំ ២០១០ មាន ៧៣,៩៣ % ; ឆ្នាំ២០១១ មាន ៧០,៤៦ % ; ឆ្នាំ២០១២ មាន ៧២,៥៦ % ; ឆ្នាំ២០១៣ មាន ៧៣,១២ % ; ឆ្នាំ២០១៤ មាន ៧៣,៩៣ % ; និងឆ្នាំ២០១៥ មាន ៧២,៤៥ % សំណើមមធ្យមក្នុងរយៈពេលពីឆ្នាំ២០១០ ទៅឆ្នាំ២០១៥ មាន ៧២,៤៩ %។ យោងតាមទិន្នន័យល្បឿនខ្យល់របស់ស្ថានីយ៍ឧតុនិយមខេត្តសៀមរាប ល្បឿនខ្យល់អប្បបរមាលើរយៈពេល ២០១០-២០១៣ មាន ០១ ម៉ែត្រ ក្នុង ០១ វិនាទី (1m/s) ល្បឿនខ្យល់មធ្យមលើរយៈពេល ២០១០-២០១៣ មាន ០៥ ម៉ែត្រ ក្នុង ០១ វិនាទី (5m/s) ល្បឿនខ្យល់អតិបរមា លើរយៈពេល ២០១០-២០១៣ មាន ១៨ ម៉ែត្រ ក្នុង ០១ វិនាទី (20m/s)។

ឋានលេខា ៖ នៅក្នុងតំបន់គម្រោងនេះជាតំបន់ខ្ពង់រាប ដែលមានរយៈកម្ពស់អប្បបរមាត្រឹម ១៦ម៉ែត្រ ម៉ែត្រ ទៅ ៨០ម៉ែត្រ ធៀបនឹងនីវ៉ូទឹកសមុទ្រ ហើយមានទីជម្រាលខ្លាំងស្ថិតនៅភាគខាងជើង និងខាងត្បូងតាមព្រំប្រទល់គម្រោងដែលមានការប្រែប្រួលពី ០-៥ ដឺក្រេ ដោយមានទីជម្រាលជាមធ្យមគឺ ៥-២០ ដឺក្រេ។

- កូគព្ភសាស្ត្រ ៖ នៅក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុនមានប្រភេទដីសំខាន់ៗចំនួន ០៤ ប្រភេទគឺ ប្រភេទដី **Acid Lithosols** ៖ មានទំហំផ្ទៃដី ១៦៨ហិកតា ស្មើនឹង ២,០៩% នៃផ្ទៃដីសម្បទានសរុបដែលស្ថិតនៅផ្នែកកណ្តាលនៃទីតាំងគម្រោង និងប៉ែកខាងត្បូងឆៀងខាងលិចនៃទីតាំងគម្រោង។ ប្រភេទដីល្បាប់ទន្លេ **Alluvial lithosols** ៖ មានទំហំផ្ទៃដី ៣.៧៨៣ហិកតា ស្មើនឹង ៤៧,២០% នៃផ្ទៃដីស្នើសុំសរុបដែលស្ថិតនៅភាគខាងលិច និងខាងកើតនៃទីតាំងគម្រោងស្នើសុំ។ ប្រភេទដី **Basic Lithosols** ៖ មានទំហំផ្ទៃដី ២៩៧ហិកតា ស្មើនឹង ៣,៧១% នៃផ្ទៃដីស្នើសុំសរុបដែលស្ថិតនៅភាគខាងត្បូងឆៀងខាងលិចនៃទីតាំងគម្រោង និង ប្រភេទដី **Plinthite Podzols** មានទំហំផ្ទៃដី ៣.៧៦៧ហិកតា ស្មើនឹង៤៧% នៃផ្ទៃដីស្នើសុំសរុប ដែលស្ថិតនៅប៉ែក ខាងជើងឆៀងខាងកើតនិងភាគខាងត្បូង នៃទីតាំងគម្រោង។ ទន្ទឹមនឹងនេះដែរ ក្រុមហ៊ុនធ្វើការវិភាគដីនៅលើទីតាំងចំនួន ០៤ ដូចខាងលើ។

ជលសាស្ត្រ៖ ក្នុងតំបន់ដីសម្បទាននេះមានប្រព័ន្ធផ្លូវទឹកមួយចំនួន ដែលមានទឹកហូរនៅគ្រប់រដូវ ដែលហូរឆ្លងកាត់ ហើយហូរបន្តចាក់ចូលប្រព័ន្ធផ្លូវទឹកសំខាន់ៗមានទឹកគ្រប់រដូវដែលស្ថិតនៅក្រៅទីតាំងគម្រោងវិនិយោគ។

ក្រុមសិក្សាបានយកសំណាកទឹក ចំនួន ០៤ សំណាក មកពិសោធន៍ដោយគោរពទៅតាមអនុក្រឹត្យលេខ ២៧អនក្រ.បក ស្តីពីការត្រួតពិនិត្យ ការបំពុលទឹក ព្រោះដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់

Draft

ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចម្រុះ និងដើម្បីបានជាលទ្ធផលគោលមួយក្នុងការប្រៀបធៀបពីផលប៉ះពាល់មុន ឬក្រោយពេលដែលមានវត្តមានគម្រោងវិនិយោគនៅក្នុងតំបន់ដូច្នេះការ យកទឹកពីតំបន់គម្រោងត្រូវបានយកមកពិសោធន៍ និងវិភាគនៅនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថានស្ថិតនៅក្រោមក្រសួងបរិស្ថាន ។

## ធនធានជីវសាស្ត្រ

ធនធានព្រៃឈើ៖ យោងតាមលទ្ធផលវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើលើសម្បទានដីសេដ្ឋកិច្ចក្នុងអនុតំបន់ទី១ ដល់ទី៣ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត លើទំហំផ្ទៃដី ៦.៤៨៨ ហិកតា ដែលមានឡូតិ៍គំរូចំនួន ៣០២ សំណាក។ ក្នុងនោះការសិក្សា គឺផ្តោតទៅលើប្រភេទព្រៃល្បោះ និងព្រៃពាក់កណ្តាលស្រោងបានបង្ហាញថា៖ ប្រភេទឈើប្រណិតមាន ៥២ប្រភេទ ដែលក្នុងនោះប្រភេទឈើប្រណិតចំនួន ៤ប្រភេទ ប្រភេទឈើលេខ១ចំនួន ១០ប្រភេទ ឈើលេខ២ចំនួន ៦ប្រភេទ ឈើលេខ៣ចំនួន ៥ប្រភេទ និងប្រភេទ ឈើក្រៅលំដាប់ថ្នាក់ចំនួន ២៧ប្រភេទ។

ធនធានសត្វព្រៃ៖ បើយោងតាមអនុក្រឹត លេខៈ ១២៣ អនក្រ.បក ពពួកទាំង ១៥ ប្រភេទនេះមិនត្រូវបានចាត់ចូលក្នុងក្រុម I II ឬ III ដែលជាក្រុមប្រភេទជិតផុងពូជ ក្រុមប្រភេទកំពុងរងគ្រោះ និងក្រុមប្រភេទងាយរងគ្រោះនោះទេ។ ដោយឡែកបើយោងតាមការផ្ទៀងផ្ទាត់ជាមួយនឹង Red List ក្នុងតំបន់ កំណែប្រែលើកទី ៣ (Version 2015.4) របស់អង្គការ IUCN យើងឃើញថាមាន ក្រុមប្រភេទរងការគម្រាមកំហែងតិចតួច (LC) ចំនួន០៩ប្រភេទ និង០៦ប្រភេទផ្សេងទៀតមិនទាន់ត្រូវបានកំណត់នៅឡើយ។

ថនិកសត្វ៖ ចំពោះពពួកថនិកសត្វ ដែលមានវត្តមានក្នុង និងក្បែរតំបន់គម្រោងមានប្រមាណ ២៩ ប្រភេទ យោងតាមប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "ស្តីពីចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃ" មានក្រុមប្រភេទមានដោយកម្រចំនួន ០៣ ប្រភេទ ក្រុមប្រភេទមានដោយបង្គួរចំនួន ១៨ប្រភេទ និងក្រុមប្រភេទមិនទាន់ត្រូវបានកំណត់ចំនួន ០៨ ប្រភេទ។ ដោយឡែក បើយោងតាមការផ្ទៀងផ្ទាត់ជាមួយនឹង Red List ក្នុងតំបន់ កំណែប្រែលើកទី ៣ (Version 2015.4) របស់អង្គការ IUCN យើងឃើញថាមាន ក្រុមប្រភេទរងការគម្រាមកំហែងតិចតួច (LC) ចំនួន ២២ ប្រភេទក្រុមប្រភេទ ជិតផុតពូជ (EN) មានចំនួន០២ប្រភេទ ប្រភេទជិតផុតពូជបំផុតចំនួន០១ប្រភេទ ក្រុមប្រភេទរងគ្រោះជិត ផុតពូជមានចំនួន ០១ប្រភេទ និង ០៣ប្រភេទ ផ្សេងទៀតមិនទាន់ត្រូវបានឲ្យអត្តសញ្ញាណនៅឡើយ។

ឧរង្គសត្វ៖ ចំពោះពពួកឧរង្គសត្វដែលមានវត្តមានក្នុង និងក្បែរតំបន់គម្រោងមានប្រមាណ ៣២ ប្រភេទ យោងតាមប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី "ចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃ" មានក្រុមប្រភេទមានដោយបង្គួរចំនួន ២៥ ប្រភេទ និងក្រុមប្រភេទមិនទាន់ត្រូវបានកំណត់ចំនួន ០៧ប្រភេទ។ ដោយឡែក បើយោងតាមការផ្ទៀងផ្ទាត់ជាមួយនឹង Red List ក្នុងតំបន់កំណែប្រែលើកទី ៣ (Version 2015.4) របស់អង្គការ IUCN យើងឃើញថាមាន ក្រុមប្រភេទ រងការគម្រាមកំហែងតិចតួច (LC) ចំនួន១៤ប្រភេទ ក្រុមប្រភេទជិតផុតពូជ (EN) មានចំនួន០១ប្រភេទ និង ១៥ប្រភេទ ផ្សេងទៀតមិនទាន់ត្រូវបានឲ្យអត្តសញ្ញាណនៅឡើយ។

Draft

បក្សី៖ ចំពោះបក្សីព្រៃដែលមានវត្តមានក្នុង និងក្បែរតំបន់គម្រោងមានប្រមាណជាង ១៧៤ ប្រភេទ យោងតាមប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពី "ចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃ" មានក្រុមប្រភេទមានដោយកម្រចំនួន ០២ប្រភេទ ក្រុមប្រភេទមានដោយបង្គួរចំនួន ១៧១ប្រភេទ និងក្រុមប្រភេទមិនទាន់ត្រូវបានកំណត់ចំនួន ០១ប្រភេទ។ ដោយឡែក បើយោងតាមការផ្ទៀងផ្ទាត់ជាមួយនឹង Red List ក្នុងតំបន់ កំណែប្រែលើកទី ៣ (Version 2015.4) របស់អង្គការ IUCN យើងឃើញថាមាន ក្រុមប្រភេទរងការគំរាមកំហែងតិចតួច (LC) ចំនួន ១៦៦ ប្រភេទ ក្រុមប្រភេទរងគ្រោះជិតផុតពូជមានចំនួន ០១ប្រភេទ ប្រភេទជិតរងគ្រោះចំនួន ០២ប្រភេទ និង០៥ប្រភេទ ផ្សេងទៀតមិនទាន់ត្រូវបានឲ្យអត្តសញ្ញាណនៅឡើយ។

មច្ឆជាតិ៖ ជាលទ្ធផលពពួកធនធានមច្ឆជាតិ ដែលមានវត្តមាននៅក្បែរតំបន់គម្រោងមានចំនួន ១៥ប្រភេទ។ បើយោងតាមអនុក្រឹត លេខ: ១២៣ អនក្រ.បក ពពួកទាំង ១៥ប្រភេទនេះមិនត្រូវបានចាត់ចូលក្នុងក្រុម I II ឬ III ដែលជាក្រុមប្រភេទជិតផុងពូជ ក្រុមប្រភេទកំពុងរងគ្រោះ និងក្រុមប្រភេទងាយរងគ្រោះនោះទេ។ ដោយឡែកបើយោងតាមការផ្ទៀងផ្ទាត់ជាមួយនឹង Red List ក្នុងតំបន់ កំណែប្រែលើកទី ៣ (Version 2015.4) របស់អង្គការ IUCN យើងឃើញថាមាន ក្រុមប្រភេទរងការគំរាមកំហែងតិចតួច (LC) ចំនួន០៩ ប្រភេទ និង០៦ប្រភេទផ្សេងទៀតមិនទាន់ត្រូវបានកំណត់នៅឡើយ។

<u>ធនធានសង្គម</u>

ធនធានសេដ្ឋកិច្ច-សង្គម គឺសំដៅទៅលើការប្រើប្រាស់ទឹក និងអនាម័យ ប្រជាសាស្ត្រ-ហេដ្ឋារចនាសម្ព័ន្ធ ទំនៀមទម្លាប់ប្រពៃណី ប្រាក់ចំណូល ប្រាក់ចំណាយ ចំណាកស្រុក ស្ថានភាពមុខរបរ និងការរស់នៅរបស់ប្រជាជននៅក្នុងតំបន់។ ការសិក្សាពីធនធានសេដ្ឋកិច្ចសង្គម គឺដើម្បីធ្វើការប៉ាន់ប្រមាណអំពីផលប៉ះពាល់ ទៅលើធនធានទាំងនោះនៅពេលដែលមានវត្តមានរបស់គម្រោង និងដើម្បីរៀបចំវិធានការការពារ ឬវិធានការកាត់បន្ថយនូវផលប៉ះពាល់ទាំងនោះ។

តាមរយៈផែនទី និងការចុះសិក្សាផ្ទាល់បានបង្ហាញថា តំបន់គម្រោងស្ថិតនៅក្នុងស្រុកជ័យសែន ខេត្តព្រះវិហារ ដូច្នេះ ការសិក្សាលើស្ថានភាពធនធានសង្គមត្រូវបានផ្តោតលើស្រុកធែប ដែលស្ថិតនៅទីតាំងគម្រោងវិនិយោគនេះតែម្តង ហើយភូមិដែលប៉ះពាល់មានដូចជា ៖ ភូមិតស៊ូ ភូមិសំពោង ឃុំតស៊ូ, ភូមិពុទ្រា ភូមិបរ ឃុំពុទ្រា, ភូមិស្វាង ភូមិគោគ ឃុំស្វាង ។ ក្រុមសិក្សាប្រើប្រាស់នូវរូបមន្ត Taro មុននឹងធ្វើការសិក្សានៃភូមិ ឃុំ ពាក់ព័ន្ធខាងលើ។

## ៦. ការចូលរួមពីសាធារណៈជន

ការពិគ្រោះយោបល់ ឬស្ទង់មតិជាសាធារណៈជាមួយមន្ទីរ និងអាជ្ញាធរពាក់ព័ន្ធ ជាផ្នែកមួយដ៏សំខាន់នៃការសិក្សាវាយតម្លៃទៅលើផលប៉ះពាល់បរិស្ថាន និងសង្គម ព្រោះការប្រមូលមតិសាធារណៈអំពីភាគីពាក់ព័ន្ធទាំងអស់អំពីបរិស្ថាន និងសង្គម ដែលកើតមានឡើងកន្លងមក ឬដែលមិនធ្លាប់កើតឡើងកន្លងមកនឹងកើតឡើងទៀតដោយសារសកម្មភាពគម្រោង។ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធមានការឯកភាព ចំពោះគម្រោងអភិវឌ្ឍ

របស់ក្រុមហ៊ុន ហេង ណុង ព្រោះការអភិវឌ្ឍន៍ធ្វើឲ្យសេដ្ឋកិច្ចក្នុងសហគមន៍ក៏ដូចជាប្រទេសជាតិមានការរីកចម្រើន ហើយការអភិវឌ្ឍន៍ស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ៧. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

នៅក្នុងជំពូកនេះគឺស្ដោតសំខាន់ទៅលើហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយនៅក្នុងដំណាក់កាលនីមួយៗ ដោយលើកនូវវិធានការមួយចំនួន ដើម្បីកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានឲ្យនៅកម្រិតអប្បបរមា និងជំរុញនូវរាល់ហេតុប៉ះពាល់បរិស្ថានវិជ្ជមាន ឲ្យដល់កម្រិតអតិបរមាដែលបណ្ដាលមកពីសកម្មភាពនៃគម្រោងអភិវឌ្ឍ។

ហើយក្រុមសិក្សាបានធ្វើការកំណត់នូវទំហំនៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយដោយធ្វើការវិភាគថាតើកម្រិតនៃការប៉ះពាល់មានកម្រិតតិច មធ្យម ខ្លាំង ដូចមានលម្អិតនៅជំពូកទី៧។

- ដំណាក់កាលមុនសាងសង់

ដំណាក់កាលនេះគម្រោងពុំទាន់មានសកម្មភាពអ្វីទេ គឺគ្រាន់តែក្រុមហ៊ុនសហការជាមួយស្ថាប័នជំនាញអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ចុះពិនិត្យ កំណត់ព្រំប្រទល់ និងឈូសឆាយផ្លូវក្រវ៉ាត់ព្រំជុំវិញទីតាំងគម្រោង។ សកម្មភាពគម្រោងប៉ះពាល់ដល់ធនធានសំខាន់ៗមួយចំនួនដូចជា៖ ធនធានព្រៃឈើ ធនធានសត្វព្រៃនិងទីជម្រក និងសតិអារម្មណ៍របស់ប្រជាជន។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុនបានសហការល្អជាមួយស្ថានប័នពាក់ព័ន្ធ ក្នុងការឈូសឆាយផ្លូវក្រវ៉ាត់ព្រំ ក៏ដូចជាមានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ។
- ក្រុមហ៊ុននិងគោរពកិច្ចសន្យាជាមួយមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគោរពតាមកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល។
- ការពិភាក្សាជាមួយប្រជាពលរដ្ឋមូលដ្ឋាន ដែលទទួលរងការប៉ះពាល់ពីការអនុវត្តន៍គម្រោង ដើម្បីផ្ដល់ជាព័ត៌មានលម្អិត ស្ដីពីការវិនិយោគដីសម្បទាន។

- ដំណាក់កាលសាងសង់

នៅក្នុងដំណាក់កាលនេះ សកម្មភាពរបស់ក្រុមហ៊ុនគឺពុំមានលក្ខណៈធំដុំទេ គឺក្រុមហ៊ុនគ្រាន់តែធ្វើការឈូសឆាយដើម្បីរៀបចំការដ្ឋាន កន្លែងស្នាក់នៅ កន្លែងបណ្ដុះពូជអំពៅ ប្រព័ន្ធស្រោចស្រព សាងសង់ផ្លូវចូលការដ្ឋានគម្រោង។ ក្នុងដំណាក់កាលនេះផងដែរ គឺប៉ះពាល់ដល់ធនធានមួយចំនួនដូចជា៖ សណ្ឋានដី និងការហូរច្រោះដី គុណភាពដី និងគុណភាពទឹកលើដី និងទឹកក្រោមដី ការរំខានដោយសំឡេង និងរំញ័រ ធនធានព្រៃឈើ និងសត្វព្រៃ ជីវៈចម្រុះក្នុងទឹក មុខរបរ និងការរស់នៅរបស់ប្រជាពលរដ្ឋ ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់សហគមន៍ សុខភាព/សុវត្ថិភាពរបស់បុគ្គលិក កម្មករ ផ្លូវគមនាគមន៍។

<u>វិធានការកាត់បន្ថយ</u>

- ការសាងសង់ស្របតាមលក្ខណៈបច្ចេកទេសដូចជា៖ ការដ្ឋាន រៀបចំកន្លែងសម្រាប់ប្រើប្រាស់ និងទុកដាក់ម៉ាស៊ីន/គ្រឿងចក្រ កន្លែងស្តុកប្រេងឥន្ធនៈ កន្លែងផ្ទុកសំណល់រឹង និងបង្គន់អនាម័យ ព្រមទាំងត្រួតពិនិត្យរថយន្តដឹកជញ្ជូនដែលថ្មីៗជាប្រចាំ។
- ធ្វើការអប់រំដល់បុគ្គលិក កម្មករ ឲ្យយល់ដឹងពីបញ្ហាមួយចំនួនដូចជា៖ ការប្រុងប្រយ័ត្នចំពោះភ្លើងឆេះព្រៃ ការបរបាញ់សត្វ និងកំណត់ពេលវេលាក្នុងម៉ោងធ្វើការ ដើម្បីកុំឲ្យមានការរំខានដោយសំឡេង ពេលជួបបញ្ហាត្រូវរាយការណ៍ដល់អាជ្ញាធរមូលដ្ឋាន ពេលប្រទះឃើញភ្លើងឆេះព្រៃដើម្បីធ្វើការទប់ស្កាត់ឲ្យបានទាន់ពេលវេលា។
- មានការផ្ដល់ទឹកស្អាត កន្លែងស្នាក់នៅ និងផ្ដល់ថ្នាំពេទ្យសម្រាប់ការសង្គ្រោះបឋម សាងសង់បង្គន់អនាម័យត្រឹមត្រូវដល់បុគ្គលិកកម្មករ។
- ធ្វើការថែទាំ និងជួសជុលផ្លូវ កំណត់ទម្ងន់ផ្ទុក និងល្បឿននៅពេលដឹកជញ្ជូនឆ្លងកាត់ដែលមាននៅតំបន់គម្រោងដើម្បីធានាឲ្យបានការប្រើប្រាស់យូរអង្វែង។
- ប្រជាពលរដ្ឋមានសិទ្ធចូល និងឆ្លងកាត់ទីតាំងគម្រោង ដើម្បីសម្រួលដល់ពួកគាត់អាចចូលរកអនុផលព្រៃឈើផ្សេងៗជាធម្មតា។
- ក្រុមហ៊ុនបានធ្វើការផ្សព្វផ្សាយ និងអប់រំឲ្យយល់ដឹងពីការថែរក្សាទំនៀមទម្លាប់ប្រពៃណី វប្បធម៌ និងជំនឿសាសនាដល់បុគ្គលិក កម្មករ ក្នុងតំបន់គម្រោង។

- **ដំណាក់កាលប្រតិបត្តិគម្រោង**

នៅក្នុងដំណាក់កាលនេះសកម្មភាពរបស់ក្រុមហ៊ុន មានលក្ខណៈយូរអង្វែងដែលរាជរដ្ឋាភិបាល បានផ្ដល់ដីសម្បទានសេដ្ឋកិច្ច សម្រាប់ធ្វើការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្មដាំដំណាំអំពៅ និងអាកាស្យា រយៈពេល ៥០ឆ្នាំ។ ក្រុមហ៊ុននឹងធ្វើការឈូសឆាយដីតាមអនុតំបន់ សាងសង់ផ្លូវមេ ផ្លូវឡូតិ៍ និងផ្លូវអនុឡូតិ៍ សាងសង់ប្រព័ន្ធជាពសាស្ត្រ អគារស្នាក់នៅសម្រាប់បុគ្គលិកកម្មករ និងការិយាល័យបន្ថែម។ ក្រោយពីការឈូសឆាយ ក្រុមហ៊ុននឹងធ្វើការដាំដុះ អំពៅនិងអាកាស្យា ទៅតាមអនុតំបន់នីមួយៗ ដូចមានចែងនៅក្នុងផែនការមេរបស់ក្រុមហ៊ុន។ សកម្មភាពនានានៅក្នុងដំណាក់កាលនេះ មានផលប៉ះពាល់ដល់ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសង្គមដូចជា៖ សណ្ឋានដី ការហូរច្រោះដី គុណភាពដី គុណភាពទឹកលើដី គុណភាពទឹកក្រោមដី គុណភាពខ្យល់ ធនធានព្រៃឈើ ធនធានសត្វព្រៃ និងទីជម្រក ជីវៈចម្រុះក្នុងទឹក សិទ្ធនៃការប្រើប្រាស់ទឹករបស់សហគមន៍ ប្រពៃណី វប្បធម៌របស់សហគមន៍មូលដ្ឋាន មុខរបរ និងប្រាក់ចំណូល ការប្រើប្រាស់ដី សុខភាព/សុវត្ថិភាពរបស់បុគ្គលិក កម្មករ ការរំខានដោយសំឡេង និងរំញ័រ ផ្លូវគមនាគមន៍ ដីប្រាសាទ ឬខឿនប្រាសាទបុរាណ ដីព្រៃសហគមន៍ជួកដង ការគ្រប់គ្រងសំណល់រឹង ការគ្រប់គ្រងសំណល់រាវ។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុននិងធ្វើការឈូសឆាយសណ្ឋានដី និងចិត្តទុកដាក់ខ្ពស់ រាល់សកម្មភាពឈូសឆាយនៅតំបន់មានទីជម្រាលទៅតាមអនុតំបន់ស្របតាមលក្ខណៈបច្ចេកទេស និងសហការជាមួយក្រសួងសាធារណៈការនិងដឹកជញ្ជូន និងក្រសួងធនធានទឹកនិង ឧតុនិយម។

- ក្រុមហ៊ុនបានសហការជាប្រចាំជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈក្នុងការកំណត់ទីតាំងទួលខឿនប្រាសាទនានាក្នុងតំបន់គម្រោងវិនិយោគ និងមិនធ្វើការឈូសឆាយបំពានដីសហគមន៍ ព្រៃឈើដោយកំណត់ព្រំ ៣០០ម៉ែត្រ ជុំវិញប្រាសាទ។
- ក្រុមហ៊ុនមានផែនការគ្រប់គ្រងសំណល់រឹង/រាវដូចជា៖ កាត់បន្ថយនូវការប្រើប្រាស់ និងកែច្នៃឲ្យងាយស្រួលក្នុងការទុកដាក់ និងរៀបចំកន្លែងស្តុកនូវប្រេងឥន្ធនៈ ប្រេងរំអិលក្នុងធុង និងសាងសង់បង្គន់អនាម័យឲ្យបានគ្រប់គ្រាន់ ណែនាំបុគ្គលិកឲ្យចេះសន្សំសំចៃក្នុងការប្រើប្រាស់ទឹក។

- ដំណាក់កាលបញ្ចប់គម្រោង

ក្រោយពីបញ្ចប់សកម្មភាពការងាររបស់ក្រុមហ៊ុន ក្រុមហ៊ុននឹងផ្ទេរដីសម្បទានសេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលផ្តល់ជូនសម្រាប់ធ្វើការវិនិយោគទៅឲ្យរដ្ឋាភិបាលវិញ។ ជាមួយគ្នានេះដែរ នៅក្នុងដំណាក់កាលនេះក៏មានជះឥទ្ធិពលតិចតួចទៅដល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គម ដូចជា៖ គុណភាពដី គុណភាពខ្យល់ ធនធានព្រៃឈើ និងសត្វព្រៃ ការប្រើប្រាស់ដី មុខរបរ និងការរស់នៅរបស់សហគមន៍មូលដ្ឋាន ផ្លូវគមនាគមន៍។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុនបានដាំដុះដើមឈើឡើងវិញទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន និងរក្សាទុកដើមអំពៅ និងអាកាស្យាសម្រាប់ធ្វើជាគម្របព្រៃ និងជួសជុលផ្លូវឡើងវិញដែលមានការខូចខាត រួចប្រគល់ដីសម្បទាននេះទៅឲ្យរាជរដ្ឋាភិបាលវិញ ហើយភារៈកិច្ចការពារដីនេះជារបស់អាជ្ញាធរមូលដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ស្ថាប័ន ពាក់ព័ន្ធក្នុងការគ្រប់គ្រង និងថែរក្សាបន្ត។
- ក្រុមហ៊ុន និងលុបកន្លែងចាក់សំរាម រួចធ្វើការសម្អាតទីធ្លាដែលបានបន្សល់ទុកនូវរបស់របរចាស់ៗ និងសំណល់រឹង-រាវផ្សេងៗដែលខ្លួនបានបោះបង់ចោលបន្ទាប់ពីបញ្ចប់គម្រោង។
- ក្រុមហ៊ុនបានសហការជាប្រចាំជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងការកំណត់ទីតាំងទួលខឿនប្រាសាទប្រសិនបើជួបប្រទះឃើញទួលខឿនប្រាសាទថ្មីៗ។
- ផ្សព្វផ្សាយដំណឹង ពីការបិតគម្រោងរបស់ក្រុមហ៊ុនទៅឲ្យបុគ្គលិក កម្មករ ដែលបម្រើការងារឲ្យបានដឹងជាមុនយ៉ាងហោចណាស់ ០៣ខែ។

Draft

## ៨. ផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថានអនុវត្តន៍ឡើង ដើម្បីធ្វើការតាមដានទៅលើការអនុវត្តន៍វិធានការកាត់បន្ថយ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលបានលើកឡើងនៅក្នុងជំពូកទី៧ ដើម្បីឲ្យប្រាកដថាពល់វិធានការទាំងអស់ដែលបានលើកឡើង ត្រូវបានអនុវត្តន៍ដោយម្ចាស់គម្រោងនូវរាល់ដំណាក់កាល ដែលគេប៉ាន់ប្រមាណថាមានហេតុប៉ះពាល់កើតឡើងដោយសារសកម្មភាពនៃគម្រោង។ ផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានរៀបចំឡើងដោយម្ចាស់គម្រោង ព្រមទាំងមានការកំណត់ឲ្យបានច្បាស់លាស់ ទៅលើទីតាំងដែលត្រូវត្រួតពិនិត្យ រយៈកាលតាមដាន និងសមាស- ភាពអ្នកចូលរួមត្រួតពិនិត្យពីសំណាក់ក្រសួងជំនាញ អាជ្ញាធរមូលដ្ឋាន និងមន្ទីពាក់ព័ន្ធនានា។

លទ្ធផលនៃការត្រួតពិនិត្យនេះ ម្ចាស់គម្រោងនឹងបញ្ជូនរបាយការណ៍ទៅឲ្យក្រសួងបរិស្ថានរៀងរាល់ ០៦ខែម្ដង (គិតចាប់ផ្ដើមពីថ្ងៃ EIA ពេញលេញត្រូវបានអនុម័ត) លើដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង។

នៅគ្រប់ដំណាក់កាលនៃគម្រោង ក្រុមហ៊ុននឹងរៀបចំកំណត់នូវវិធានការមួយចំនួន ដើម្បីធ្វើការទប់ស្កាត់ និងកាត់បន្ថយរាល់ហេតុប៉ះពាល់អវិជ្ជមាន ដែលកើតមានឡើងដោយសារសកម្មភាពរបស់គម្រោង និងដើម្បីធានាការគ្រប់គ្រងធនធានបរិស្ថាន ក្នុងតំបន់នោះប្រកបដោយប្រសិទ្ធភាព ស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថាន។ កម្មវិធីបំពាក់បំប៉ន នឹងត្រូវរៀបចំដោយក្រុមហ៊ុនដើម្បីកសាងសមត្ថភាពរបស់បុគ្គលិក កម្មករឲ្យបានរីកចម្រើន។

ក្នុងរយៈពេល៥០ឆ្នាំនៃការវិនិយោគរបស់ខ្លួន ដើម្បីទប់ទល់ទៅនឹងការបាត់បង់ព្រៃឈើ ដោយសារសកម្មភាពឈូសឆាយ ក្រុមហ៊ុននឹងចំណាយថវិកាចំនួន ១.២៥០.០០០ដុល្លារអាមេរិក សម្រាប់ចូលរួមក្នុងមូលនិធិបរិស្ថាន និងសម្រាប់ចូលរួមអភិវឌ្ឍន៍ភូមិ-ឃុំ ដូចជាដំណើរការបណ្ដុះបណ្ដាលវិជ្ជាជីវៈបច្ចេកទេសជំនាញនានា រួមមាន ការដាំដុះ ចិញ្ចឹមសត្វ វារីវប្បកម្ម ចូលរួមអភិរក្សជលផល និងការការពារអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ និងសោភ័ណភាពបរិស្ថានក្នុងតំបន់។ លើសពីនេះទៅទៀត ក្នុងរយៈពេល៥០ឆ្នាំនេះដែរ ក្រុមហ៊ុនក៏បានចំណាយថវិកាចំនួន ៣.២៥០.០០០ ដុល្លារអាមេរិក សម្រាប់ការស្ដាមូនិធិសង្គមមានដូចជាៈ ការអប់រំបច្ចេកទេសដាំដុះ និងផ្ដល់ពូជដំណាំអំពៅ និងអាកាស្យា ការជួសជុល និងកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជាៈ ផ្លូវ ស្ពាន មណ្ឌលសុខភាព អណ្ដូងទឹក បង្គន់អនាម័យជាដើម។

## ៩. ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

ជំពូកនេះ ផ្ដោតជាសំខាន់ទៅលើការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន ដោយធ្វើការប្រៀបធៀបជាមួយនឹងការចូលរួមចំណែករបស់គម្រោងអភិវឌ្ឍ ទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបរិស្ថាន។ គោលបំណងចម្បងក្នុងការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន គឺដើម្បីបង្ហាញឲ្យច្បាស់នូវផលចំណេញ ឬខាតបង់ក្នុងកម្រិតណាមួយដល់បរិស្ថាន និងសង្គម បើធៀបនឹងហេតុប៉ះពាល់អវិជ្ជមានដោយគម្រោង។

តាមរយៈការគណនាតម្លៃសក្ដានុពល ដែលទទួលបានពីវិស័យព្រៃឈើអាចមានដូចជា សេវាកម្មស្តុកកាបូនមានប្រមាណជា ៤.៨០៥.៥៧៣ ដុល្លារអាមេរិក/ឆ្នាំ តម្លៃសេវាកម្មអភិរក្សទឹក និងដីមានប្រមាណជា ៤៦២.៧៤៣ ដុល្លារអាមេរិក/ឆ្នាំ ចំណែកឯតម្លៃដែលទទួលបានពីផល និងអនុផលព្រៃឈើមានប្រមាណជា ២២៣.០៥២ ដុល្លារអាមេរិក/ឆ្នាំ។

ដោយឡែក តាមរយៈការវិភាគតម្លៃ ឱកាសនៃការបាត់បង់ផលចំណេញពី វិស័យបរិស្ថានធម្មជាតិបានបង្ហាញថាតម្លៃឱកាសពីការប៉ាន់ប្រមាណនៃការបាត់បង់សម្រាប់វិស័យស្តុកនិងស្រូបកាបូន មានប្រមាណជា ៤.៥៩០.០០០ដុល្លាអាមេរិក/ឆ្នាំ ការបាត់បង់តម្លៃឱកាសនៃសេវាកម្មអភិរក្សទឹក និងដីមានប្រមាណជា ២៣.១៣៧.១៥០ដុល្លាអាមេរិក/ឆ្នាំ ខណៈដែលតម្លៃឱកាសពីការបាត់បង់ផលចំណេញពី ផល-អនុផលព្រៃឈើមានប្រមាណជា ១១.១៥២.៦០០ដុល្លាអាមេរិក/ឆ្នាំ។ ទោះជាយ៉ាងណាក្ដី តម្លៃនៃការខាតបង់នេះ មិនមែនជាតម្លៃនៃការខាតបង់សេដ្ឋកិច្ចសុទ្ធសាធនោះទេ។ តម្លៃដែលបានប៉ាន់ស្មាន គឺជាតម្លៃខូចខាតដោយសារបាត់បង់ឱកាសទទួលបានផលិតផល សេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ក្នុងករណីព្រៃឈើទាំងនោះត្រូវបានគ្រប់គ្រងដោយ

Draft

និន្តរភាព ដើម្បីទទួលបានផល-អនុផលព្រៃឈើ សេវាកម្មអភិរក្សទឹក សេវាកម្មអភិរក្សដី និងសេវាកម្មស្តុកកាបូន។ ដូច្នេះដើម្បីគ្រប់គ្រងព្រៃឈើទាំងនោះ ឲ្យមាននិរន្តរភាពទាមទារនូវថវិកាជាច្រើនដែលយើងមិនអាចប៉ាន់ស្មានបាន ដូច្នេះគម្រោងវិនិយោគនេះ ពិតជាផ្តល់ផលចំណេញជាសាច់ប្រាក់សុទ្ធសម្រាប់សេដ្ឋកិច្ចជាតិ ពិសេសបានចូលរួមចំណែកក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលតាមរយៈការផ្តល់ការងារធ្វើជូនដល់ប្រជាជននៅក្នុងមូលដ្ឋាន និងរួមចំណែក នៅក្នុងការបង្កើនសេដ្ឋកិច្ចប្រទេស តាមរយៈការបង់ពន្ធជូនប្រទេសជាតិទាំងមូល។

## ១០. សន្និដ្ឋាន និងអនុសាសន៍

តាមការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ គម្រោងនេះនឹងបង្កហេតុប៉ះពាល់ដល់ធនធានមួយចំនួនដូចជា ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម។ ផលប៉ះពាល់ចំពោះធនធាន រូបសាស្ត្រមានដូចជា: ការប៉ះពាល់ដល់គុណភាពទឹកលើដី និងក្រោមដី ស្ថេរភាពនៃធនធានទឹកលើដី និងក្រោមដី។ ពាក់ព័ន្ធទៅនឹងធនធានជីវសាស្ត្រ វាមានការប៉ះពាល់ដល់ធនធានព្រៃឈើ និងសត្វព្រៃ ប្រសិនបើគ្មានការរក្សាទុកនូវតំបន់ដែលជាទីជម្រករបស់វានោះទេ។

ក្រៅពីនោះ គម្រោងនេះក៏នឹងប៉ះពាល់ដល់ការប្រើប្រាស់ទឹក ប្រសិនណាប្រភពទឹកនានារងការបំពុល។ ការប្រើប្រាស់ប្រភពថាមពល និងជីវភាពរស់នៅរបស់ពួកគាត់ក៏នឹងរងនូវការប៉ះពាល់ផងដែរ។ ព្រោះតាមការសិក្សាលើប្រជាជនទាំងអស់ ដែលរស់នៅដោយពឹងផ្អែកមួយចំនួនលើធនធានព្រៃឈើទាំងនេះ។ ទោះជាយ៉ាងណាវត្តមាននៃគម្រោងវិនិយោគនេះ ក៏នឹងអាចផ្តល់មកវិញនូវផលប្រយោជន៍ជាច្រើនដល់ប្រជាជនមូលដ្ឋាន និងប្រទេសជាតិទាំងមូល តាមរយៈការបង្កើនឲ្យមានការងារធ្វើសម្រាប់ប្រជាជនពេញវ័យ និងប្រជាជនស្ថិតនៅក្នុងក្រុមអាយុប្រជាជនសកម្ម ការអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ និងបង្កើននូវចំណេះដឹង និងបទពិសោធន៍ដល់ប្រជាជនក្នុងមូលដ្ឋានដែលពាក់ព័ន្ធជាមួយនឹងផលិតកម្មដំណាំអំពៅ។

Draft

ដើម្បីធ្វើការកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថាន និងសង្គមឲ្យបានដល់កម្រិតអតិប្បរមា ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់ចូលរួមថែរក្សាប្រភេទឈើ ឬបណ្តុំព្រៃសម្រាប់ជីវៈចម្រុះ រក្សាទុកដីព្រៃទ្រនាប់ជងអូរយ៉ាងតិច ៥០-១០០ ម៉ែត្រសងខាងអូរដោះស្រាយរាល់បញ្ហាដីស្រែ-ចម្ការរបស់ប្រជាជន ដែលមានពាក់ព័ន្ធនៅក្នុងតំបន់គម្រោង និងត្រូវមានផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ ឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារការបំពុលបរិស្ថានធម្មជាតិ និងជាពិសេសប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជនមូលដ្ឋាន។

ជាពិសេស ក្រុមហ៊ុនវិនិយោគត្រូវគោរពតាមឲ្យបានខ្ជាប់ខ្ជួននូវកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល និងអនុវត្តន៍ឲ្យបាននូវផែនការគ្រប់គ្រងបរិស្ថានឲ្យមានប្រសិទ្ធភាព ព្រមទាំងសហការល្អជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសក្រសួងបរិស្ថានក្នុងការត្រួតពិនិត្យសម្របសម្រួល និងដោះស្រាយបញ្ហាទៅតាមកម្មវិធីត្រួតពិនិត្យបរិស្ថានដែលមានក្នុងរបាយការណ៍នេះ។